**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៣៧ អនក្រ.បក**

នា.មចធ មកដល់
ថ្ងៃទី... ខែ... ឆ្នាំ...
ម៉ោង... ចុះលេខបញ្ជី...

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់រង្វាន់ដល់ជ័យលាភីសិស្សពូកែ ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការរៀបចំថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យា
- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងផ្ដល់រង្វាន់ដល់ជ័យលាភីសិស្សពូកែទូទាំងប្រទេស ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅៈ

- សម្រិតសម្រាំងសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ
- លើកទឹកចិត្តសិស្សនៅមធ្យមសិក្សាឱ្យផ្ដោតការយកចិត្តទុកដាក់លើអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ
- ផ្ដល់តម្លៃដល់ជ័យលាភីសិស្សពូកែ។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះជ័យលាភីសិស្សពូកែទូទាំងប្រទេសនៅតាមគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈនិងឯកជនថ្នាក់ទី៩និងថ្នាក់ទី១២។

## ជំពូកទី២

## ការប្រឡងជ្រើសរើសសិស្សពូកែ

**មាត្រា៤ .-**

ការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្តផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ ថ្នាក់ទី៩ និងថ្នាក់ទី១២ ត្រូវរៀបចំឡើងដោយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រថ្នាក់ទី៩ និងថ្នាក់ទី១២ត្រូវរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៥ .-**

យន្តការនិងនីតិវិធីនៃការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្តថ្នាក់ទី៩ និងថ្នាក់ទី១២ និងយន្តការនិងនីតិវិធីនៃការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសថ្នាក់ទី៩និងថ្នាក់ទី១២ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៦ .-**

ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសថ្នាក់ទី៩និងថ្នាក់ទី១២ ត្រូវប្រព្រឹត្តទៅនៅរាជធានីភ្នំពេញឬទីរួមខេត្តណាមួយ ទាំងដំណើរការសំណេរ កំណែ ស្រង់ បូកពិន្ទុនិងប្រកាសលទ្ធផលប្រឡង។

វិញ្ញាសាប្រឡងត្រូវចេញដោយក្រសួងអប់រំ យុវជន និងកីឡា ដោយផ្អែកលើកម្មវិធីសិក្សាចាប់ពីថ្នាក់ទី៧ដល់ថ្នាក់ទី៩ សម្រាប់ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសថ្នាក់ទី៩ និងផ្អែកលើកម្មវិធីសិក្សាចាប់ពីថ្នាក់ទី៧ដល់ថ្នាក់ទី១២ សម្រាប់ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសថ្នាក់ទី១២។

**មាត្រា៧ .-**

ក្នុងការប្រឡងជ្រើសរើសសិស្សពូកែតាមឆ្នាំសិក្សានីមួយៗ បេក្ខជនម្នាក់ៗមានសិទ្ធិជ្រើសរើសបានតែមួយមុខវិជ្ជាគត់ក្នុងចំណោមមុខវិជ្ជាទាំងបី។

**មាត្រា៨ .-**

គណៈមេប្រយោគប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស ត្រូវបំពេញការងារតាមចំនួនថ្ងៃជាក់ស្តែង និងទទួលប្រាក់ឧបត្ថម្ភតាមរបបម៉ោងបន្ថែមដោយគិតក្នុងមួយថ្ងៃបំពេញការងារ៦(ប្រាំមួយ)ម៉ោងបន្ថែម ហើយប្រាក់កំរៃមួយម៉ោងបន្ថែមស្មើប្រាក់កម្រៃនៃមួយម៉ោងបន្ថែមរបស់គ្រូមធ្យមសិក្សាទុតិយភូមិ។

ការចាត់តាំងគណៈមេប្រយោគ និងគណៈកម្មការផ្សេងៗសម្រាប់ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស ជាសមត្ថកិច្ចរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៩ .-**

ថវិកាប្រឡងសម្រាប់ចំណាយលើសម្ភារៈចាំបាច់ផ្សេងៗ ការរៀបចំពិធីបើកការប្រឡង និងពិធីចែករង្វាន់ សោហ៊ុយធ្វើដំណើរ ស្នាក់នៅ ហូបចុករបស់ប្រតិភូរាជធានី ខេត្ត និងបេក្ខជន និងចំណាយសម្រាប់រៀបចំដំណើរកម្សាន្តរបស់បេក្ខជន ជាបន្ទុករបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី៣

## រង្វាន់និងការលើកទឹកចិត្ត

**មាត្រា១០ .-**

ជ័យលាភីសិស្សពូកែទូទាំងប្រទេស ត្រូវទទួលបានរង្វាន់និងការលើកទឹកចិត្តពីរាជរដ្ឋាភិបាលដូចខាងក្រោម៖

១. ប្រកាសស្តីពីការទទួលស្គាល់សិស្សពូកែ ដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មួយច្បាប់

២. មេដាយមួយគ្រឿង សម្រាប់បេក្ខជនជ័យលាភីចំណាត់ថ្នាក់ពីលេខ១ដល់លេខ៣

៣. វិញ្ញាបនបត្របញ្ជាក់សិស្សពូកែទូទាំងប្រទេស មួយច្បាប់

៤. ប្រាក់រង្វាន់តាមចំណាត់ថ្នាក់៖

- ចំណាត់ថ្នាក់លេខ១ ៣ ៥០០ ០០០ (បីលានប្រាំសែន)រៀល
- ចំណាត់ថ្នាក់លេខ២ ៣ ២០០ ០០០ (បីលានពីរសែន)រៀល
- ចំណាត់ថ្នាក់លេខ៣ ២ ៩០០ ០០០ (ពីរលានប្រាំបួនសែន)រៀល
- ចំណាត់ថ្នាក់លេខ៤ ២ ៦០០ ០០០ (ពីរលានប្រាំមួយសែន)រៀល
- ចំណាត់ថ្នាក់លេខ៥ ២ ៣០០ ០០០ (ពីរលានបីសែន)រៀល
- ចំណាត់ថ្នាក់លេខ៦ ២ ០០០ ០០០ (ពីរលាន)រៀល
- ចំណាត់ថ្នាក់លេខ៧ ១ ៧០០ ០០០ (មួយលានប្រាំពីរសែន)រៀល
- ចំណាត់ថ្នាក់លេខ៨ ១ ៤០០ ០០០ (មួយលានបួនសែន)រៀល
- ចំណាត់ថ្នាក់លេខ៩ ១ ១០០ ០០០ (មួយលានមួយសែន)រៀល
- ចំណាត់ថ្នាក់លេខ១០ ៨០០ ០០០ (ប្រាំបីសែន)រៀល

បុគ្គល បុព្វជិត គ្រួសារ សហគមន៍ សង្គមស៊ីវិល ស្ថាប័នរដ្ឋនិងឯកជនទាំងអស់ មានសិទ្ធិផ្តល់រង្វាន់ជាសម្ភារៈ ឬថវិកាជូនជ័យលាភីសិស្សពូកែ។

**មាត្រា១១ .-**

ក្រសួងអប់រំ យុវជន និងកីឡាមានភារកិច្ចរៀបចំពិធីបើកការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស និងរៀបចំពិធីចែករង្វាន់ដល់ជ័យលាភីសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ ឱ្យបានសមរម្យ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

អនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការរៀបចំថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ហង់ ជួន ណារ៉ុន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខៈ ០១ អយក.សណន

# សេចក្តីណែនាំ
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅ នៃការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្ត និងទូទាំងប្រទេសឆ្នាំ ២០១៧

ដើម្បីពង្រឹងគុណភាពអប់រំ និងអភិវឌ្ឍធនធានមនុស្សប្រកបដោយសីលធម៌ និងចំណេះដឹងខ្ពស់ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំពីការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្ត និងទូទាំងប្រទេសនៅគ្រឹះស្ថានមធ្យមសិក្សា តាមខ្លឹមសារដូចខាងក្រោម៖

**១- ការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្ត**

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវម្ចាស់ការរៀបចំការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្តផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា ថ្នាក់ទី៩ និងថ្នាក់ទី១២ នៅក្នុងខែមីនា តាមលទ្ធភាព និងគំនិតច្នៃប្រឌិតផ្ទាល់ តាមមុខវិជ្ជា និងតាមថ្នាក់នីមួយៗ រួចបញ្ជូនបេក្ខភាពមកចូលរួមប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសតាមចំនួនដូចកំណត់ក្នុងតារាងបែងចែកជូនភ្ជាប់មកជាមួយនេះ។

ចំពោះសិស្សថ្នាក់ទី៩ និងទី១២ នៃគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅឯកជនអាចចូលរួមក្នុងការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្ត តាមរាជធានី ខេត្តរបស់ខ្លួនជាមួយគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈដែរ។

ដោយឡែកវិទ្យាល័យអនុវត្ត ត្រូវចូលរួមប្រឡងជ្រើសរើសសិស្សពូកែថ្នាក់រាជធានីជាមួយគ្រឹះស្ថានមធ្យមសិក្សានានាក្រោមឱវាទមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ។

ប្រធានវិញ្ញាសាប្រឡងជ្រើសរើសសិស្សពូកែតាមរាជធានី ខេត្ត ជាសមត្ថកិច្ចរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តសាមី។

**២- ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស**

ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា ថ្នាក់ទី ៩ និងថ្នាក់ទី ១២ ប្រព្រឹត្តទៅចាប់ពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៧ និងថ្ងៃបន្តបន្ទាប់នៅមណ្ឌលវិទ្យាល័យព្រះមុនីវង្ស ខេត្តបាត់ដំបង។

មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង និងសាមីគ្រឹះស្ថានសិក្សាដែលត្រូវយកធ្វើជាមណ្ឌលប្រឡង មានភារកិច្ចរៀបចំមណ្ឌលប្រឡង និងសម្ភារៈចាំបាច់សម្រាប់ការប្រព្រឹត្តទៅ នៃការប្រឡងឱ្យហើយស្រេច មុនបើកសម័យប្រឡង ហើយត្រូវសហការជាមួយនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ក្នុងការរៀបចំពិធីបើក ពិធីបិទ ចែករង្វាន់ និងដំណើរការកំសាន្តរបស់បេក្ខជន។

មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង មានភារកិច្ចអញ្ជើញអភិបាល នៃគណៈអភិបាលខេត្ត ដើម្បីថ្លែងសុន្ទរកថាស្វាគមន៍ក្នុងពិធីបើក និងចូលរួមជាភ្ញៀវកិត្តិយស អមដោយកងកម្លាំងមានសមត្ថកិច្ច និងមន្ទីរពាក់ព័ន្ធក្នុងខេត្ត នៅក្នុងពិធីបើក ពិធីបិទ និងចែករង្វាន់ដល់ជ័យលាភីសិស្សពូកែទូទាំងប្រទេស ហើយត្រូវរៀបចំកម្មវិធីដំណើរកំសាន្តរបស់បេក្ខជន ដោយធ្វើលិខិតជូនដំណឹងទៅអាជ្ញាធរខេត្ត ដើម្បីស្នើ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៤៧ / ២១៧ ២៥៣ / ៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ: www.moeys.gov.kh

សុំកម្លាំងមានសមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋានឱ្យជូនដំណើរ រក្សាសន្តិសុខ សុវត្ថិភាព និងជួយសម្របសម្រួលលើការងារផ្សេងៗ សំដៅធ្វើឱ្យដំណើរកំសាន្តនេះប្រព្រឹត្តទៅប្រកបដោយជោគជ័យ។

ប្រតិភូប្រចាំរាជធានី ខេត្តនីមួយៗ មានភារកិច្ចដឹកនាំ គ្រប់គ្រងបេក្ខជនសិស្សពូកែរបស់ខ្លួន ចាប់តាំងពីពេលចេញដំណើរពីរាជធានី ខេត្តខ្លួន រហូតដល់ពេលត្រឡប់ទៅដល់រាជធានី ខេត្តរបស់ខ្លួនវិញ ជាពិសេសត្រូវចុះជាប់ជាមួយសិស្សនៅពេលធ្វើដំណើរកំសាន្ត ចៀសវាងដាច់ខាតកុំឱ្យកើតមានបញ្ហាជាយថាហេតុ។

សិស្សពូកែទាំងអស់ត្រូវស្លៀកពាក់ជាឯកសណ្ឋានសិស្ស ដោយប្រើអាវពណ៌ស និងខោ ឬសំពត់ពណ៌ខៀវស៊កចូលក្នុងខោ ឬសំពត់ឱ្យបានត្រឹមត្រូវនៅពេលចូលមណ្ឌលប្រឡង និងត្រូវចូលរួមពិធីបើក និងបិទការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស។

ប្រធានវិញ្ញាសាប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ដោយគិតតាមកម្មវិធីសិក្សាពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩ សម្រាប់សិស្សថ្នាក់ទី៩ និងពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២ សម្រាប់សិស្សថ្នាក់ទី១២។

បេក្ខជនសិស្សពូកែម្នាក់ អាចជ្រើសរើសមុខវិជ្ជាឯកទេស ដើម្បីធ្វើការប្រឡងបានតែមួយមុខវិជ្ជាប៉ុណ្ណោះក្នុងចំណោមអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា។ បេក្ខជនម្នាក់ៗ ត្រូវធ្វើការប្រឡងជាបីពេល គឺមុខវិជ្ជាឯកទេសដែលខ្លួនបានជ្រើសរើសចំនួនពីរពេល និងមុខវិជ្ជាវប្បធម៌ទូទៅចំនួនមួយពេល។

ដើម្បីសម្រួលដល់ការគណនាលេខ ក្រសួងបានត្រៀមម៉ាស៊ីនគិតលេខ សម្រាប់បេក្ខជនសិស្សពូកែមុខវិជ្ជារូបវិទ្យាទាំងថ្នាក់ទី៩ និងថ្នាក់ទី១២ ខ្ចីប្រើប្រាស់ក្នុងពេលប្រឡង។

**២.១- ការប្រព្រឹត្តទៅនៃដំណើរការប្រឡង**

* ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៧
  * ពេលព្រឹក ៖ ប្រធាន អនុប្រធានមណ្ឌលប្រជុំណែនាំសមាជិកគណៈមេប្រយោគ នៅមណ្ឌលវិទ្យាល័យព្រះមុនីវង្ស ខេត្តបាត់ដំបង
  * ពេលរសៀល ៖ ប្រារព្ធពិធីបើកការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស វេលាម៉ោង ១៤ : ០០ នៅវិទ្យាល័យព្រះមុនីវង្ស ខេត្តបាត់ដំបង។
* ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៧
  * ពេលព្រឹក ៖ - ដំណើរការសំណេរវិញ្ញាសាទី១មុខវិជ្ជាឯកទេសអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា (ថ្នាក់ទី៩ និងទី១២)
    - គណៈកម្មការកំណែ ៖ ធ្វើអត្រាកំណែតាមមុខវិជ្ជា តាមកម្រិតថ្នាក់
    - គណៈកម្មការកណ្ដាលកំណែ ៖ ពិនិត្យផ្ទៀងផ្ទាត់ ចុះអក្សរសម្ងាត់ និងកាត់ក្បាលសន្លឹកកិច្ចការបេក្ខជន។
  * ពេលរសៀល ៖ កែកិច្ចការបេក្ខជន។
* ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៧
  * ពេលព្រឹក ៖ - ដំណើរការសំណេរមុខវិជ្ជាវប្បធម៌ទូទៅ ( ថ្នាក់ទី៩ និងទី១២ )
    - គណៈកម្មការកំណែ ៖ ធ្វើអត្រាកំណែវប្បធម៌ទូទៅ និងបន្តកែ
    - គណៈកម្មការកណ្ដាលកំណែ ៖ ពិនិត្យផ្ទៀងផ្ទាត់ ចុះអក្សរសម្ងាត់ និងកាត់ក្បាលសន្លឹកកិច្ចការបេក្ខជន។
  * ពេលរសៀល ៖ កែកិច្ចការបេក្ខជន។
* ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៧
  * ពេលព្រឹក ៖ - ដំណើរការសំណេរវិញ្ញាសាទី២មុខវិជ្ជាឯកទេសអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា (ថ្នាក់ទី៩ និងទី១២)
    - គណៈកម្មការកំណែ ៖ ធ្វើអត្រាកំណែតាមមុខវិជ្ជា តាមកម្រិតថ្នាក់

- គណៈកម្មការកណ្ដាលកំណែ ៖ ពិនិត្យផ្ទៀងផ្ទាត់ ចុះអក្សរសម្ងាត់ និងកាត់ក្បាលសន្លឹកកិច្ចការបេក្ខជន។

* ពេលរសៀល ៖ កែកិច្ចការបេក្ខជន។

* ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៧

- បន្តកែកិច្ចការបេក្ខជន
- នាំបេក្ខជនសិស្សពូកែធ្វើដំណើរកំសាន្ត តាមរមណីយដ្ឋានវប្បធម៌ និងធម្មជាតិ។

* ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧

- បន្តកែកិច្ចការបេក្ខជន
- ស្រង់ បូកពិន្ទុ និងពិនិត្យផ្ទៀងផ្ទាត់ពិន្ទុ
- នាំបេក្ខជនសិស្សពូកែធ្វើដំណើរកំសាន្ត តាមរមណីយដ្ឋានវប្បធម៌ និងធម្មជាតិ។

* ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៧

- គណៈកម្មការគ្រប់គ្រងទូទៅប្រជុំពិនិត្យសម្រេចលទ្ធផលប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស
- បោះពុម្ពប្រកាសទទួលស្គាល់សិស្សពូកែ និងវិញ្ញាបនបត្រសិស្សពូកែទូទាំងប្រទេស។

* ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៧

* ពេលព្រឹក ៖ រៀបចំពិធីបិទការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស។

* ពេលរសៀល ៖ ប្រារព្ធពិធីបិទ និងពិធីចែករង្វាន់ដល់ជ័យលាភីសិស្សពូកែទូទាំងប្រទេសប្រចាំឆ្នាំ២០១៧ វេលាម៉ោង ១៤ : ០០ នៅវិទ្យាល័យព្រះមុនីវង្ស ខេត្តបាត់ដំបង។

### ២.២- រយៈពេល និងរបបពិន្ទុ នៃវិញ្ញាសានីមួយៗ ថ្នាក់ទី៩ និងថ្នាក់ទី១២

- អក្សរសិល្ប៍ខ្មែរ : ១៨០ នាទី ១០០ពិន្ទុ
- គណិតវិទ្យា : ១៨០ នាទី ១០០ពិន្ទុ
- រូបវិទ្យា : ១៨០ នាទី ១០០ពិន្ទុ
- វប្បធម៌ទូទៅ : ១២០ នាទី ១០០ពិន្ទុ។

### ២.៣- សំណុំលិខិតរបស់បេក្ខជន

ក្រោយពីបានធ្វើការប្រឡងជ្រើសរើសសិស្សពូកែនៅតាមរាជធានី ខេត្តរួចហើយ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវធ្វើបញ្ជីរាយនាមបេក្ខភាពសិស្សពូកែតាមមុខវិជ្ជាឯកទេស តាមកម្រិតថ្នាក់(គំរូជូនភ្ជាប់ទី១) ដោយភ្ជាប់មកជាមួយនូវ Soft copy ដោយប្រើកម្មវិធីគ្រប់គ្រងទិន្នន័យនៅមធ្យមសិក្សា (សម្រាប់មន្ទីរ) គ្រាន់តែ click (√ ) នៅក្នុងប្រអប់ជ្រើសរើសសិស្សពូកែ និងជ្រើសរើសយកមុខវិជ្ជាមួយក្នុងប្រអប់មុខវិជ្ជាជាការស្រេច។ ចំពោះរូបថត Digital តម្រូវឱ្យសិស្សពាក់អាវស ពាក់ស្លាកឈ្មោះលើហោប៉ៅអាវខាងឆ្វេង និងពាក្យសុំចុះឈ្មោះប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស (គំរូជូនភ្ជាប់ទី២) ដោយភ្ជាប់មកជាមួយនូវសំបុត្របញ្ជាក់កំណើត (ថតចម្លង) ដើម្បីជៀសវាងខុសឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត របស់បេក្ខជន ហើយផ្ញើមកក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ការិយាល័យប្រឡង) ឱ្យបានមុនថ្ងៃ ទី ២៤ ខែ មីនា ឆ្នាំ ២០១៧ ជាកំហិត។

### ២.៤- លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសជ័យលាភីសិស្សពូកែ

១- បេក្ខជនណាមិនគោរពបទប្បញ្ញត្តិនៃការប្រឡង ដូចជាលួចមើលសំណៅផ្សេងៗ ងាកមើលអ្នកជិតខាង ឬសួរគ្នា នឹងត្រូវជម្រុះចោល។

២- បេក្ខជនណាដែលពិន្ទុវប្បធម៌ទូទៅក្រោមមធ្យមភាគ នឹងត្រូវជម្រុះ ប៉ុន្តែពិន្ទុវប្បធម៌ទូទៅមិនត្រូវបានយកទៅបូកនឹងពិន្ទុមុខវិជ្ជាឯកទេសឡើយ។

៣- បេក្ខជនណាដែលបានពិន្ទុវប្បធម៌ទូទៅលើមធ្យមភាគ ប៉ុន្តែពិន្ទុសរុបលើមុខវិជ្ជាឯកទេសក្រោមមធ្យមភាគនោះ ក៏ត្រូវជម្រុះចោលដែរ។

៤- បេក្ខជនណាបានពិន្ទុវប្បធម៌ទូទៅលើមធ្យមភាគ និងពិន្ទុសរុបលើមុខវិជ្ជាឯកទេសលើមធ្យមភាគ ត្រូវកំណត់ជាជម្រើសសម្រាប់ប្រជែងជាជ័យលាភីសិស្សពូកែ តាមមុខវិជ្ជាឯកទេស តាមកម្រិតថ្នាក់ ដោយជ្រើសរើសយកពីលំដាប់ពិន្ទុខ្ពស់បំផុត មកពិន្ទុទាបជាបន្តបន្ទាប់រហូតដល់ចំណាត់ថ្នាក់លេខ១០។

៥- ក្នុងករណីបេក្ខជនដែលបានពិន្ទុវប្បធម៌ទូទៅ និងពិន្ទុសរុបតាមមុខវិជ្ជាឯកទេស លើមធ្យមភាគមិនគ្រប់ចំនួន១០ជ័យលាភីនោះ ត្រូវកំណត់យកតាមចំនួនជ័យលាភីជាក់ស្តែង។

៦- ក្នុងករណីពិន្ទុសរុបលើមុខវិជ្ជាឯកទេសស្មើគ្នា ត្រូវអញ្ជើញប្រធាន ឬអនុប្រធានកំណៃ កែកិច្ចការនោះសាជាថ្មីឡើងវិញ តាមបែបកំណែសម្ងាត់។

៧- ក្នុងករណីកែឡើងវិញ ពិន្ទុនៅតែស្មើគ្នាទៀតនោះ នឹងត្រូវសម្រេចផ្តល់អាទិភាពជូនបេក្ខជន ជានារី។

៨- គ្រប់សន្លឹកកិច្ចការ ត្រូវកែជារបៀបសម្ងាត់ទាំងអស់។ សន្លឹកកិច្ចការបេក្ខជនម្នាក់ ត្រូវកែដោយអ្នកកែពីរនាក់ផ្សេងៗពីគ្នា ដោយដាក់ពិន្ទុសម្ងាត់រៀងៗខ្លួន ហើយពិន្ទុនោះមិនត្រូវសរសេរលើសន្លឹកកិច្ចការបេក្ខជនឡើយ។ ក្រោយពីកែរួច អ្នកកែត្រូវយករបាយពិន្ទុលម្អិតជាសម្ងាត់នោះ មកប្រគល់ជូនប្រធានក្រុមកំណៃ ដើម្បីបញ្ជូនទៅគណៈកម្មការកណ្តាល។ របាយពិន្ទុលម្អិតរបស់អ្នកកែទាំងពីរនាក់ សម្រាប់កិច្ចការបេក្ខជនម្នាក់ នឹងត្រូវយកមកផ្គូផ្គងផ្ទៀងផ្ទាត់ឡើងវិញ។

ក្នុងករណីគម្លាតពិន្ទុរវាងអ្នកកែទាំងពីរ ៖

- មុខវិជ្ជាអក្សរសិល្ប៍ខ្មែរ និងវប្បធម៌ទូទៅ ៖ ក្រោម ឬស្មើ ១០ ពិន្ទុ
- មុខវិជ្ជាគណិតវិទ្យា និងរូបវិទ្យា ៖ ក្រោម ឬស្មើ ៥ ពិន្ទុ

ត្រូវសម្រេចយកមធ្យមភាគ នៃពិន្ទុរបស់អ្នកកែទាំងពីរនាក់

ប៉ុន្តែក្នុងករណីគម្លាតពិន្ទុរវាងអ្នកកែទាំងពីរ ៖

- មុខវិជ្ជាអក្សរសិល្ប៍ខ្មែរ និងវប្បធម៌ទូទៅ ៖ ធំជាង ១០ ពិន្ទុ
- មុខវិជ្ជាគណិតវិទ្យា និងរូបវិទ្យា ៖ ធំជាង ៥ ពិន្ទុ

ត្រូវរៀបចំឱ្យកែជាលក្ខណៈសម្ងាត់ឡើងវិញម្តងទៀត។

### ២.៥- ផលប្រយោជន៍ដែលជ័យលាភីសិស្សពូកែត្រូវទទួលបាន

បេក្ខជនគ្រប់រូបសុទ្ធតែបានទទួលវិញ្ញាបនបត្រចូលរួមប្រឡងសិស្សពូកែថ្នាក់ជាតិម្នាក់១សន្លឹក។ ជ័យលាភីសិស្សពូកែម្នាក់ៗ ត្រូវទទួលបានរង្វាន់ និងការលើកទឹកចិត្តពីរាជរដ្ឋាភិបាលតាមចំណាត់ថ្នាក់ដូចខាងក្រោម ៖

- **ចំណាត់ថ្នាក់លេខ១** ៖ ប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ វិញ្ញាបនបត្រសិស្សពូកែទូទាំងប្រទេស ១សន្លឹក មេដាយមាស ១គ្រឿង និងថវិកា ៣ ៥០០ ០០០ (បីលានប្រាំសែន) រៀល
- **ចំណាត់ថ្នាក់លេខ២** ៖ ប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ វិញ្ញាបនបត្រសិស្សពូកែទូទាំងប្រទេស១សន្លឹក មេដាយប្រាក់១គ្រឿង និងថវិកា ៣ ២០០ ០០០(បីលានពីរសែន)រៀល
- **ចំណាត់ថ្នាក់លេខ៣** ៖ ប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ វិញ្ញាបនបត្រសិស្សពូកែទូទាំងប្រទេស១សន្លឹក មេដាយសំរិទ្ធ១គ្រឿង និងថវិកា២ ៩០០ ០០០(ពីរលានប្រាំបួនសែន)រៀល

- **ចំណាត់ថ្នាក់លេខ៤** ៖ ប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ វិញ្ញាបនបត្រសិស្សពូកែទូទាំងប្រទេស ១សន្លឹក និងថវិកា ២ ៦០០ ០០០ (ពីរលានប្រាំមួយសែន) រៀល
- **ចំណាត់ថ្នាក់លេខ៥** ៖ ប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ វិញ្ញាបនបត្រសិស្សពូកែទូទាំងប្រទេស ១សន្លឹក និងថវិកា ២ ៣០០ ០០០ (ពីរលានបីសែន) រៀល
- **ចំណាត់ថ្នាក់លេខ៦** ៖ ប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ វិញ្ញាបនបត្រសិស្សពូកែទូទាំងប្រទេស ១សន្លឹក និងថវិកា ២ ០០០ ០០០ (ពីរលាន) រៀល
- **ចំណាត់ថ្នាក់លេខ៧** ៖ ប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ វិញ្ញាបនបត្រសិស្សពូកែទូទាំងប្រទេស ១សន្លឹក និងថវិកា ១ ៧០០ ០០០ (មួយលានប្រាំពីរសែន) រៀល
- **ចំណាត់ថ្នាក់លេខ៨** ៖ ប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ វិញ្ញាបនបត្រសិស្សពូកែទូទាំងប្រទេស ១សន្លឹក និងថវិកា ១ ៤០០ ០០០ (មួយលានបួនសែន) រៀល
- **ចំណាត់ថ្នាក់លេខ៩** ៖ ប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ វិញ្ញាបនបត្រសិស្សពូកែទូទាំងប្រទេស ១សន្លឹក និងថវិកា ១ ១០០ ០០០ (មួយលានមួយសែន) រៀល
- **ចំណាត់ថ្នាក់លេខ១០** ៖ ប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ វិញ្ញាបនបត្រសិស្សពូកែទូទាំងប្រទេស ១សន្លឹក និងថវិកា ៨០០ ០០០ (ប្រាំបីសែន) រៀល។

* **សម្គាល់** ៖ ជ័យលាភីសិស្សពូកែ អាចមានប្រាក់រង្វាន់ ឬវត្ថុផ្សេងៗបន្ថែម ពីសប្បុរសជន។

### ២.៦- ការចំណាយ និងពេលវេលាត្រូវទៅដល់ខេត្តបាត់ដំបង របស់បេក្ខជនសិស្សពូកែ និងគណៈប្រតិភូរាជធានី ខេត្ត

ប្រតិភូដឹកនាំសិស្សពូកែទូទាំងប្រទេស ត្រូវនាំសិស្សពូកែទៅដល់វិទ្យាល័យព្រះមុនីវង្ស ខេត្តបាត់ដំបង នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៧ វេលាម៉ោង ១៤ : ០០ រសៀល ដើម្បីប្រារព្ធពិធីបើកការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស។

ការចំណាយលើសោហ៊ុយរៀបចំពិធីបើកការប្រឡង ពិធីចែករង្វាន់ និងសោហ៊ុយធ្វើដំណើរ ស្នាក់នៅ ហូបចុក សម្រាប់ដំណើរការប្រឡង និងដំណើរកំសាន្តរបស់បេក្ខជន ជាបន្ទុករបស់ក្រសួងអប់រំ យុវជន និងកីឡា។

សូមជូនភ្ជាប់មកជាមួយនូវ ៖

- តារាងបែងចែកបេក្ខជនសិស្សពូកែ និងប្រតិភូតាមរាជធានី ខេត្ត
- គំរូបញ្ជីរាយនាមបេក្ខភាពប្រឡងសិស្សពូកែទូទាំងប្រទេស (គំរូទី១)
- គំរូពាក្យសុំចុះឈ្មោះប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស (គំរូទី២)

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថា លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡាគ្រប់រាជធានី ខេត្ត នឹងផ្សព្វផ្សាយសេចក្តីណែនាំនេះដល់គ្រប់គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងឯកជនក្នុងរាជធានី ខេត្ត ព្រមទាំងអនុវត្តសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមករា ឆ្នាំ ២០១៧

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
" ដើម្បីជ្រាបជាព័ត៌មាន "
- សាលារាជធានី ខេត្ត
-អង្គភាពក្រោមឱវាទទីស្តីការក្រសួងអយក
-មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
" ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ នា.មចទ